# ការជ្រាបអំពីប្រសិទ្ធភាពរបស់ថ្នាំ ផ្សះ

Know when Antibiotics Work
WUML
10/12/08

សប្ដាហ៍កន្លងមកនេះ ជាសប្ដាហ៍ដែលក្រសួងសាធារណៈសុខាភិបាលអប់រំ អំពីគ្រោះថ្នាក់ផ្សេងៗ ដែលបណ្ដាលមកពីការសម ឬធននឹងថ្នាំផ្សះ ដែលហៅថា Antibiotics Resistance។ ហើយក៏ជាសប្ដាហ៍ ដែលគួរជ្រាប អំពីវិធីផ្សេងៗ ដែលអាចការពារកុំឲ្យសមឬធននឹងថ្នាំទាំងនេះ ផងដែរ។

ការសមឬធននឹងថ្នាំផ្សះ ដែលហៅថា Antibiotics Resistance ជាបញ្ហាផ្នែកសាធារណៈសុខាភិបាលមួយដែល ចោទឡើងទូទាំងពិភពលោក ទាំងមូល។ លក្ខណៈនេះ កើតឡើងនៅពេលណា ដែលមេរោគបាក់តេរី មានកម្លាំងខ្លាំង ពុំអាចធ្វើថ្នាំផ្សះ មានប្រសិទ្ធភាពល្អបាន។

ការប្រើថ្នាំផ្សះ ដែលពុំបានត្រឹមត្រូវទៅតាមវិធីប្រើ អាចជាកត្តាមួយ ដែលបណ្ដាលឲ្យមេរោគបាក់តេរី ធននឹងថ្នាំផ្សះនោះ។ ដូច្នេះ នៅពេលក្រោយ ដែលលោកអ្នកត្រូវការប្រើថ្នាំផ្សះ នោះទៀត វាពុំអាចមានប្រសិទ្ធភាពបានឡើយ។

ថ្នាំផ្សះពុំអាចមានប្រសិទ្ធ សំរាប់ព្យាបាល នៅពេលលោកអ្នកមានរោគគ្រុនផ្ដាសាយធម្មតា ឬគ្រុនផ្ដាសាយធំនោះឡើយ។ រោគគ្រុនផ្ដាសាយធម្មតា និងគ្រុនផ្ដាសាយធំបណ្ដាលមកពីមេរោគវៃរើស ពុំមែនមកពីមេរោគបាក់តេរីទេ។ ការប្រើថ្នាំផ្សះ នៅពេលមានរោគដោយសារមេរោគវៃរើស អាចធ្វើឲ្យមានផលវិបត្តច្រើនជាងគុណសម្បត្តិ។ ដូច្នេះ ជាការចាំបាច់ដែលគួរជ្រាបថា តើពេលណាដែលត្រូវប្រើថ្នាំផ្សះ Antibiotics ឬពេលណាដែលពុំត្រូវប្រើ។

ការប្រើថ្នាំ ផ្សះ Antibiotics សំរាប់រោគ ដូចជារោគ គ្រុនផ្ដាសាយធម្មតា, គ្រុនផាសាយធំ, ឬរោគរលាកទងសួតខ្លាំងដែលហៅថា acute bronchitis:

- ពុំអាចព្យាបាលរោគនេះ ឲ្យបានជាសះស្បើយឡើយ
- ពុំការពារអ្នកជម្ងឺ កុំឲ្យធ្លាក់ខ្លួនឈឺទៀតបាន
- ពុំអាចធ្វើឲ្យអ្នកជម្ងឺ ស្រួលខ្លួនវិញ
- មិនត្រឹមតែប៉ុណ្ណោះសោត វាអាចបណ្ដាលឲ្យមានផលវិបត្តផ្សេងៗទៀតផងដែរ

ដូច្នេះ តើលោកអ្នកគួរធ្វើយ៉ាងដូចម្ដេច ដើម្បីកុំឲ្យសមឬធននឹងថ្នាំផ្សះ Antibiotics នោះ?

- សូមមេត្តា កុំសុំថ្នាំផ្សះពីគ្រូពេទ្យ នៅពេលដែលគាត់យល់ថា ថ្នាំនោះ ពុំអាចជួយព្យាបាលលោកអ្នកបាន។
- សូមមេត្តាកុំប្រើថ្នាំផ្សះ សំរាប់រោគ ដែលបណ្តាលមកពីមេរោគវៃរើស។ ដូចជា រោគគ្រុនផ្តាសាយធម្មតា, រោគក្អក, ឬរោគគ្រុនផ្តាសាយធំ ជាដើម។
- សូមមេត្តា កុំយកថ្នាំផ្សះ ដែលគ្រូពេទ្យចេញឲ្យសំរាប់អ្នកដទៃ ទៅលេប។ ពីព្រោះថ្នាំនោះ ប្រហែលជា ពុំត្រូវ សំរាប់រោគរបស់លោកអ្នកឡើយ។
- តែ ប្រសិនបើគ្រូពេទ្យ ចេញថ្នាំផ្សះ សំរាប់ឲ្យលោកអ្នកលេបវិញ សូមមេត្តា៖
    - លេបកុំឲ្យខាន
    - សូមមេត្តា កុំសន្សំទុកសំរាប់លេបទៅ ថ្ងៃក្រោយទៀត ឲ្យសោះ។

យោលទៅតាម មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺនៃសហរដ្ឋ, U.S. Center for Disease Control and Prevention, ដើម្បីឲ្យបានស្រួលខ្លួន នៅពេលលោកអ្នក មានបញ្ហា តឹងច្រមុះពីបាកដកដង្ហើម លោកអ្នកពុំត្រូវការថ្នាំផ្សះ Antibiotics ឡើយ គឺ ដោយគ្រាន់តែ៖

- ទទួលទានទឹកឲ្យបានគ្រប់គ្រាន់
- សំរាកឲ្យបានច្រើន
- ប្រើម៉ាស៊ិនបញ្ចេញចំហាយទឹក ឬប្រើថ្នាំបាញ់ច្រមុះ កុំឲ្យតឹង និង
- បាញ់ស្រ្តេបំពង់ក, ឬបៀមស្កសំរាប់ឲ្យរអិលបំពង់ក (តែកុំឲ្យក្មេងប្រើស្កនេះ)

ម្យ៉ាងទៀត សូមចោលថ្នាំ ផ្សះដែលពុំប្រើឲ្យបានត្រឹមត្រូវ។ លាងដៃឲ្យបានញឹកញាប់ ជាពិសេស មុនពេលទទួលទានអាហារ និងក្រោយពេលចាប់សត្វលេង ដូចជា ឆ្កែឆ្មាជាដើម។ ហើយសូមអញ្ជើញទៅ ចាក់ថ្នាំបង្ការោគឲ្យបានគ្រប់ចំនួន។

ចំពោះពត៌មាន បន្ថែមស្តីអំពីការសមឬធននឹងថ្នាំ ផ្សះ Antibiotics សូមមេត្តាអានវិបសៃរបស់មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺនៃសហរដ្ឋ, U.S. Center for Disease Control and Prevention, ដែលមានអាសយដ្ឋាន www.cdc.gov/drugresistance/community ។

Source: U.S. Center for Disease Control and Prevention: www.cdc.gov/Feature/GetSmart